**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**

**ប្រ.ក/លេខ១០.០៤១/០៧ គ.ជ.ប.អគ្គ.ពស** ភ្នំពេញ ថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០០៧

# សន្និសីទសារព័ត៌មានវាយតម្លៃអំពីការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត

នៅថ្ងៃទី ២៣ ខែ តុលា ឆ្នាំ ២០០៧ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ( គ.ជ.ប ) បានធ្វើការវាយតម្លៃអំពីដំណើរការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត នៅក្នុងសន្និសីទសារព័ត៌មានថា បានបញ្ចប់ទៅដោយរលូន និងតាមការកំណត់របស់ប្រតិទិន គ.ជ.ប ។

ឯកឧត្តម ហាវ៉ាណ ស៊ីរីល័យ សមាជិក គ.ជ.ប និងជាប្រធានដឹកនាំអង្គសន្និសីទបានមានប្រសាសន៍ថា ការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត ចាប់ពីថ្ងៃទី ១៥ ខែ កញ្ញា ដល់ថ្ងៃទី ២០ ខែ តុលា ឆ្នាំ ២០០៧ បានបញ្ចប់ទៅដោយលទ្ធផលល្អប្រសើរ ប៉ុន្តែនៅឃុំចំនួន២ គឺ ឃុំ ប៉ោយប៉ែត និងអំពិលប្រាំដើម ដែល គ.ជ.ប ពុំទាន់បានទទួលលទ្ធផលដោយសារឃុំទាំង២នេះត្រូវបន្ថែមរយៈពេលនៃការចុះឈ្មោះបោះឆ្នោត ៤ថ្ងៃ ទៀត ។ ហើយបច្ចុប្បន្ន គ.ជ.ប កំពុងត្រៀមអនុវត្តការងាររបស់ខ្លួនបន្តទៀត គឺការដោះស្រាយបណ្តឹងទាក់ទងពីការបិទផ្សាយបញ្ជីដំបូង និងការផ្តល់សុពលភាពបញ្ជីបោះឆ្នោតនេះ ។

ទាក់ទងនឹងលទ្ធផលបណ្តោះអាសន្ននៃការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតនេះដែរ ឯកឧត្តម ទេព នីថា អគ្គលេខាធិការ គ.ជ.ប បានមានប្រសាសន៍ថា គិតត្រឹមថ្ងៃទី ២០ ខែ តុលា ឆ្នាំ ២០០៧ ស្មៀនឃុំ សង្កាត់ ចុះឈ្មោះបានចំនួន **៨៩៣.១៣១** នាក់ ស្មើនឹង **១៣០,៨៧** ភាគរយ នៃចំនួនប៉ាន់ស្មានអ្នកចុះឈ្មោះបោះឆ្នោត **៦៨២.៤៥៩** នាក់ ហើយលទ្ធផលនេះ ទទួលបានពីឃុំ សង្កាត់ ចំនួន **១.៦១២** ក្នុងចំណោមឃុំ សង្កាត់ **១.៦២១** ទូទាំងប្រទេស ។ ឯកឧត្តមបានបញ្ជាក់ថា ចាប់ពីថ្ងៃទី ២០ ខែ តុលា ឆ្នាំ ២០០៧ ក្រុមប្រឹក្សាឃុំ សង្កាត់ (កបឃ/ស) ត្រូវប្រជុំសម្រេចលើបញ្ជីឈ្មោះដែលត្រូវលុបចេញពីបញ្ជីបោះឆ្នោត ចុងក្រោយឆ្នាំ ២០០៦ (ទម្រង់ ១០២៥) ។

ក្នុងអង្គសន្និសីទនោះ តំណាងគណបក្សនយោបាយ និងអង្គការមិនមែនរដ្ឋាភិបាល មានការព្រួយបារម្ភខ្លាច កបឃ/ស អនុវត្តមិនបានត្រឹមត្រូវតាមបទបញ្ជា និងនីតិវិធីរបស់ គ.ជ.ប ចំពោះការប្រជុំសម្រេចលើទម្រង់ ១០២៥ ។

ទាក់ទងនឹងការព្រួយបារម្ភនេះ ឯកឧត្តម ទេព នីថា បានបំភ្លឺថា គ.ជ.ប បានចេញសេចក្តីណែនាំមួយយ៉ាងលំអិតដល់ កបឃ/ស នៅទូទាំងប្រទេស កាលពីថ្ងៃទី ៥ ខែ កញ្ញា ឆ្នាំ ២០០៧ ចំពោះការប្រជុំសម្រេចលើទម្រង់ ១០២៥ ហើយការប្រជុំសម្រេចត្រូវធ្វើតាមនីតិវិធី ដោយផ្អែកលើឯកសារភស្តុតាង ។

ឯកឧត្តមបានសង្កត់ធ្ងន់ថា ករណីពិនិត្យឃើញថា មានភាពមិនប្រក្រតី ហើយមានភស្តុតាងច្បាស់លាស់ គេអាចដាក់ពាក្យប្តឹងតវ៉ា ឬជំទាស់ តាមលំដាប់នៃនីតិវិធីទៅថ្នាក់ឃុំ សង្កាត់ ថ្នាក់ គ.ជ.ប និងក្រុមប្រឹក្សាធម្មនុញ្ញ នៅក្នុងអំឡុងពេលនៃការបិទផ្សាយបញ្ជីដំបូង ។

BtmanbEnmsmTnakTngTrsBe I x³ 023 214 374 / 012 855 018 E-mail: necinfo@forum.org.kh, Web-site : www.necelect.org.kh